# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការ
ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី
លេខ ៦២ រប-៩៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការ ខេត្តពោធិសាត់**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីការបំភ្លឺលើនីតិវិធីព្រហ្មទណ្ឌ ។

**យោង:** លិខិតលេខ ៦២ រប-៩៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៥ របស់តុលាការខេត្តពោធិសាត់ ។

ខ្ញុំសូមលោកចៅក្រមជ្រាបពីនីតិវិធី ដែលទាក់ទងនឹងសំណួរដូចខាងក្រោម៖

១-ចំពោះសំណុំរឿងព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាបញ្ជូនផ្ទាល់ទៅចៅក្រមជំនុំជម្រះ ឬ ចៅក្រមស៊ើបអង្កេតបញ្ជូនទៅចៅក្រមជំនុំជម្រះរួចហើយនៅពេលសវនាការចៅក្រមជំនុំជម្រះយល់ឃើញថា សំណុំរឿងពុំទាន់ច្បាស់គ្រប់គ្រាន់បានសម្រេចចេញសាលក្រមរបៀប ។

ការសម្រេចចាត់របៀបមានពីរករណីៈ

ក-ចាត់របៀបដោយបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញា ឬទៅចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតបន្ថែមនូវចំណុចទាំងឡាយណាដែលចៅក្រមជំនុំជម្រះយល់ឃើញថាមាននៅខ្វះចន្លោះ ។

ខ-ចាត់របៀបធ្វើការស៊ើបអង្កេតបំពេញបន្ថែមដោយខ្លួនឯង បើចៅក្រមជំនុំជម្រះយល់ឃើញថាចំនុចខ្វះចន្លោះនោះមានលក្ខណៈបន្តិចបន្តួចមិនចាំបាច់បញ្ជូនទៅព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតឡើងវិញទេ ។ ក្នុងរឿងនេះ ចៅក្រមជំនុំជម្រះដដែលត្រូវតែធ្វើការជំនុំជម្រះលើសំណុំរឿងនេះច្បាប់មិនតម្រូវឱ្យផ្លាស់ប្តូរចៅក្រមជំនុំជម្រះផ្សេងទៀតទេ ។

២-ព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេតលើជនល្មើសតែម្នាក់ ។ ចៅក្រមស៊ើបសួរបានធ្វើការស៊ើបអង្កេតលើសំណុំរឿងនេះហើយមានលេចចេញជនល្មើសផ្សេងទៀត ។ ចៅក្រមស៊ើបអង្កេតបានធ្វើការសុំឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់បន្ថែម ។ ក្នុងករណីជនល្មើសថ្មីនោះជាមន្ត្រីរាជការ ព្រះរាជអាជ្ញាមុននឹងធ្វើការចោទប្រកាន់ជូនទៅចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរលើជននោះព្រះរាជអាជ្ញាត្រូវតែសុំសេចក្តីអនុញ្ញាតិចោទប្រកាន់ពីសាមីស្ថាប័ននោះជាមុនតាមមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ទើបចាត់ការតាមនីតិវិធីតទៅទៀត ការសុំនេះត្រូវធ្វើតាមរយៈរដ្ឋមន្ត្រីក្រសួងក្រសួងយុត្តិធម៌ ។

៣-ជនល្មើសជាមន្ត្រីរាជការ ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់រួចហើយ ហើយបានបញ្ជូនសំណុំរឿង ទៅអោយចៅក្រមស៊ើបអង្កេតចៅក្រមយល់ឃើញថាត្រូវចាប់ខ្លួនជនល្មើស បញ្ហានេះចៅក្រមស៊ើបអង្កេតត្រូវបង្វិលទៅឱ្យព្រះរាជអាជ្ញាវិញ ដើម្បីឱ្យធ្វើលិខិតសុំអនុញ្ញតិធ្វើការចោទប្រកាន់មន្ត្រីរាជការរូបនេះ ទៅស្ថាប័នសាមីតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សិន ។ ក្រោយពីបានការអនុញ្ញាតិពីស្ថាប័នសាមីរួចហើយ ទើបចៅក្រមស៊ើបអង្កេតចេញដីកាចាប់ខ្លួនជនល្មើសបានក្នុងករណីបទល្មើសមិនជាក់ស្តែង ។

សេចក្តីណែនាំនេះក្រសួងយល់ឃើញថា លោកចៅក្រមប្រាកដជាយកទៅអនុវត្តឲ្យបានល្អប្រសើរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រី**

**ចែម សួន**

<u>ចម្លងជូន</u>

-តុលាការ និងអយ្យការ ខេត្ត ក្រុង

-ដើម្បីអនុវត្ត